ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

Nº ១១៣៣ ឧរម.អរជក.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែ តុលា ឆ្នាំ២០០...

# ប្រកាសបណ្ដោះអាសន្ន
## ស្ដីពី
## ការកំណត់ថ្លៃសំរាប់ការបង់ថ្លៃចុះបញ្ជី ពាក្យសុំ(កម្រែអាជ្ញាប័ណ្ណ) ការពន្យារបន្ត និងការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## សម្រេច

**ប្រការ ១ :**

អ្នកដាក់ពាក្យសុំ ឬសម្បទានិកដែលមានអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវបង់ជូនរដ្ឋនូវថ្លៃចុះបញ្ជីពាក្យសុំ(កម្រែអាជ្ញាប័ណ្ណ) ការពន្យារបន្ត និងការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែ នៅអគ្គនាយកដ្ឋានធនធានរ៉ែនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ថ្លៃចុះបញ្ជី ពាក្យសុំ(កម្រែអាជ្ញាប័ណ្ណ) ការពន្យារបន្ត និងការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវបានកំណត់ដូចខាងក្រោម :

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣

Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

## ១.១ ថ្លៃចុះបញ្ជី

១- អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ .................................... ហាសិបពាន់ (៥០.០០០) រៀល

២- អាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម សំរាប់ :

២-១ ខ្សាច់សំណង់, ឡាតេរីត, ដីឥដ្ឋ............................ បួនរយពាន់ (៤០០.០០០) រៀល

២-២ ថ្មសំណង់, ថ្មអារ, គ្រួស, ម្នាងសិលា និងថ្មផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា .......... ប្រាំបីរយពាន់ (៨០០.០០០) រៀល

៣- អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ......................... ពីរលាន (២.០០០.០០០) រៀល

៤- អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ......................................... បួនរយពាន់ (៤០០.០០០) រៀល

៥- អាជ្ញាប័ណ្ណស្វែងរុករក ................................................ ប្រាំបីរយពាន់ (៨០០.០០០) រៀល

៦- អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ .................. មួយលានពីររយពាន់(១.២០០.០០០) រៀល

## ១.២ ថ្លៃពាក្យសុំ(កម្រៃអាជ្ញាប័ណ្ណ)

១- អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ .................................... សែសិបពាន់ (៤០.០០០) រៀល

២- អាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម សំរាប់ :

២-១ ខ្សាច់សំណង់, ឡាតេរីត, ដីឥដ្ឋ............................ ប្រាំមួយរយពាន់(៦០០.០០០) រៀល

២-២ ថ្មសំណង់, ថ្មអារ, គ្រួស, ម្នាងសិលា និងថ្មផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ........ មួយលានប្រាំមួយរយពាន់ (១.៦០០.០០០) រៀល

៣- អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ....................... ប្រាំបីលាន (៨.០០០.០០០) រៀល

៤- អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមាន :

៤.១- កំលាំងពលកម្មតិចជាង៧នាក់ ............................ ប្រាំបីរយពាន់ (៨០០.០០០) រៀល

៤.២- កំលាំងពលកម្ម ៧នាក់ - ១៤ នាក់ ..................... មួយលានប្រាំមួយរយពាន់ (១.៦០០.០០០) រៀល

៤.៣- កំលាំងពលកម្មលើសពី ១៤ នាក់ ........................ បីលានពីររយពាន់ (៣.២០០.០០០) រៀល

៥- អាជ្ញាប័ណ្ណស្វែងរុករក ............................................... ប្រាំមួយលាន(៦.០០០.០០០) រៀល

៦- អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ................ ដប់ពីរលាន(១២.០០០.០០០) រៀល

## ១.៣ ថ្លៃពន្យារបន្ត

១- អាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម សំរាប់ :

១-១ ខ្សាច់សំណង់, ឡាតេរីត, ដីឥដ្ឋ............................ បួនរយម្ភៃពាន់(៤២០.០០០) រៀល

១-២ ថ្មសំណង់, ថ្មអារ, គ្រួស,ម្នាងសិលា និងថ្មផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ........... មួយលានមួយរយម្ភៃពាន់ (១.១២០.០០០) រៀល

២- អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ......................... ប្រាំលានប្រាំមួយរយពាន់ (៥.៦០០.០០០) រៀល

៣- អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមាន :

៣.១- កំលាំងពលកម្មតិចជាង៧នាក់ ........................... ប្រាំរយហុកសិបពាន់(៥៦០.០០០) រៀល

៣.២- កំលាំងពលកម្ម ៧ នាក់ - ១៤ នាក់ ..................... មួយលានមួយរយម្ភៃពាន់

| | |
|---|---|
| | (១.១២០.០០០) រៀល |
| ៣.៣- កំលាំងពលកម្មលើសពី ១៤ នាក់ ........................ | ពីរលានពីររយសែសិបពាន់ (២.២៤០.០០០) រៀល |
| ៤- អាជ្ញាប័ណ្ណស្វែងរុករក ............................................. | បួនលានពីររយពាន់ (៤.២០០.០០០) រៀល |
| ៥- អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ .................. | ប្រាំបីលានបួនរយពាន់ (៨.៤០០.០០០) រៀល |

## ១.៤ ថ្លៃផ្ទេរសិទ្ធិ

| | |
|---|---|
| ១- អាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម សំរាប់ : | |
| ១-១ ខ្សាច់សំណង់, ឡាតេរីត, ដីឥដ្ឋ............................ | ពីរលាន(២.០០០.០០០) រៀល |
| ១-២ ថ្មសំណង់, ថ្មអារ, ក្រួស, ម្នាងសិលា និងថ្មផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ........... | ប្រាំបីលាន (៨.០០០.០០០) រៀល |
| ២- អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ .......................... | ដប់ប្រាំមួយលាន(១៦.០០០.០០០) រៀល |
| ៣- អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមាន : | |
| ៣.១- កំលាំងពលកម្មតិចជាង៧នាក់ ............................. | ពីរលាន(២.០០០.០០០) រៀល |
| ៣.២- កំលាំងពលកម្ម ៧នាក់ - ១៤ នាក់ ...................... | បួនលាន(៤.០០០.០០០) រៀល |
| ៣.៣- កំលាំងពលកម្មលើសពី ១៤ នាក់ ........................ | ប្រាំមួយលាន(៦.០០០.០០០) រៀល |
| ៤- អាជ្ញាប័ណ្ណស្វែងរុករក ............................................... | ម្ភៃលាន(២០.០០០.០០០) រៀល |
| ៥- អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ................... | ម្ភៃបួនលាន(២៤.០០០.០០០) រៀល |

## ប្រការ ២ :

ការគ្រប់គ្រងចំណូលដែលបានមកពីការបង់ថ្លៃចុះបញ្ជី ពាក្យសុំ(កម្រៃអាជ្ញាប័ណ្ណ) ការពន្យារបន្ត និងការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវអនុវត្តតាមនីតិវិធីនៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ ។

## ប្រការ ៣ :

ប្រាក់ចំណូលដែលបានមកពីការបង់ថ្លៃចុះបញ្ជី ពាក្យសុំ(កម្រៃអាជ្ញាប័ណ្ណ) ការពន្យារបន្ត និងការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវបង់ចូលនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលដោយភ្ជាប់មកជាមួយនូវសលាកប័ត្របង់ចំណូលទាំងអស់ដែលអនុវត្តបាន។

នៅរៀងរាល់ដំណាច់ខែនីមួយៗ អគ្គនាយកដ្ឋានធនធានរ៉ែត្រូវធ្វើរបាយការណ៍ប្រចាំខែជូនរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលអំពីចំណូលដែលបានបង់ចូលថវិការដ្ឋដោយថតចម្លងនិងភ្ជាប់មកជាមួយនូវសលាកប័ត្របង់ចំណូលទាំងអស់ ។

## ប្រការ ៤ :

អង្គភាពពាក់ព័ន្ធក្រោមចំណុះក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ព្រមទាំងសម្បទានិកពាក់ព័ន្ធក្នុងវិស័យនេះ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសបណ្តោះអាសន្ននេះ ។

ប្រការ ៥ :

ប្រកាសបណ្ដោះអាសន្ននេះមានប្រសិទ្ធភាព និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ដូចប្រការ ៤ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ